# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

លេខ: ០៣០ គ.ជ.ប. ស.ស.រ

# សេចក្តីសម្រេច
## ស្តីពី
## ការតែងតាំងសមាសភាពគណៈកម្មការរៀបចំការបោះឆ្នោតខេត្តព្រៃវែង

## គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣១៥/០០២ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣១៥/០០៣ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៥/៣២៧ ចុះថ្ងៃទី១០ ខែមេសា ឆ្នាំ២០១៥ ស្តីពីការតែងតាំងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦១៥/៦៨៨ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៥ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខណ្ឌមន្ត្រីរាជការនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- បានឃើញអនុក្រឹត្យលេខ ១០៦ អនក្រ.បក ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- បានឃើញអនុក្រឹត្យលេខ ២៦ អនក្រ.បក ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០១៦ ស្តីពីការគ្រប់គ្រង និងការប្រើប្រាស់មន្ត្រីជាប់កិច្ចសន្យា
- បានឃើញបទបញ្ជាផ្ទៃក្នុង លេខ ១១៩៨/១២ គ.ជ.ប ចុះថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១២ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- បានឃើញសេចក្តីសម្រេចលេខ ១៣៨/១៥ គ.ជ.ប.ស.ស.រ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ ស្តីពីការរៀបចំរចនាសម្ព័ន្ធរបស់នាយកដ្ឋាន និងតួនាទី ភារកិច្ចរបស់ការិយាល័យ និងលេខាធិការដ្ឋានគណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត
- ស្មារតីអង្គប្រជុំរបស់ គ.ជ.ប នាថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០១៧

## សម្រេច

**ប្រការ១.-**

ត្រូវបានតែងតាំងជាសមាសភាពគណៈកម្មការរៀបចំការបោះឆ្នោត ឱ្យបម្រើការងារនៅគណៈកម្មការរៀបចំការបោះឆ្នោតខេត្តព្រៃវែង សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ឆ្នាំ២០១៧ ដូចមានរាយនាមខាងក្រោម ៖

| ល.រ | នាមត្រកូល និងនាមខ្លួន | ភេទ | តួនាទី | រយៈពេលបម្រើការងារ |
|---|---|---|---|---|
| ១ | វង្ស សោភ័ណ | ប | ប្រធានគណៈកម្មការរៀបចំការបោះឆ្នោតខេត្តព្រៃវែង | ០៤-០២-១៧ ដល់ ៣០-០៦-១៧ |

| | | | | |
|---|---|---|---|---|
| ២ | សេង រ័ត្ន | ប | អនុប្រធានគណៈកម្មការរៀបចំការបោះឆ្នោតខេត្តព្រៃវែង | ០៤-០២-១៧ ដល់ ៣០-០៦-១៧ |
| ៣ | សំ ស៊ីនឿន | ប | សមាជិកទទួលបន្ទុកផ្នែករដ្ឋបាល | ០៤-០២-១៧ ដល់ ៣០-០៦-១៧ |
| ៤ | លាង ឡូន | ប | សមាជិកទទួលបន្ទុកផ្នែកប្រតិបត្តិការនិងបញ្ជីបោះឆ្នោត | ០៤-០២-១៧ ដល់ ៣០-០៦-១៧ |
| ៥ | ឡី ស៊ីថា | ប | សមាជិកទទួលបន្ទុកផ្នែកហិរញ្ញវត្ថុ | ០៤-០២-១៧ ដល់ ៣០-០៦-១៧ |
| ៦ | សាន់ សុផារិទ្ធ | ប | សមាជិកទទួលបន្ទុកផ្នែកបណ្តុះបណ្តាលអប់រំអ្នកបោះឆ្នោត ព័ត៌មាន និងទំនាក់ទំនងសាធារណៈ | ០៤-០២-១៧ ដល់ ៣០-០៦-១៧ |
| ៧ | រស់ ឈុនលី | ប | សមាជិកទទួលបន្ទុកផ្នែកសេវាកម្មច្បាប់ វិវាទកម្ម និងសន្តិសុខបោះឆ្នោត | ០៤-០២-១៧ ដល់ ៣០-០៦-១៧ |

**ប្រការ២..**

អគ្គលេខាធិការ នៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ប្រធានគណៈកម្មការរៀបចំការបោះឆ្នោតខេត្តព្រៃវែង និងសាមីខ្លួនត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមមុខការរៀងៗខ្លួនឱ្យមានប្រសិទ្ធភាព ។

*រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ កុម្ភៈ ឆ្នាំ២០១៧*

**ជ.គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

**ប្រធាន**

**សិក ប៊ុនហុក**

**កន្លែងទទួល** :
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងមុខងារសាធារណៈ
- សាលាខេត្តព្រៃវែង
  "ដើម្បីជូនជ្រាប"
- ដូចប្រការ២
  "ដើម្បីអនុវត្ត"
- ឯកសារ កាលប្បវត្តិ